នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-2012, 10:48
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលដាក់សេចក្ដីសន្និដ្ឋានបន្ថែម ដើម្បីគាំទ្រចំពោះបណ្ដឹងសាទុក្ខផ្សេងៗប្រឆាំងនឹង សេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្ដីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម មុំ មុន្នីចរិយា
ចៅក្រម C. N. JAYASINGHE
ចៅក្រម ស៊ិន រិទ្ធ

**ចម្លងជូន:**
ជនជាប់ចោទ:
អៀង ធីរិទ្ធ

មេធាវីការពារក្ដីជនជាប់ចោទ:
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS

ចៅក្រម យ៉ា ណារិន
ចៅក្រម F.N.M. MUMBA

**សហមេធាវីនាំមុខតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៨២(៦), ១០៥, ៣៩(៤) និង ១០៧ នៃវិធានផ្ទៃក្នុង[1] និងមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ[2] ថ្ងៃនេះ សហព្រះរាជអាជ្ញាបានដាក់ជូនបណ្តឹងសាទុក្ខភ្លាមៗ (“បណ្តឹងសាទុក្ខ”) ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសម្បទាក្នុងការចូលរួមសវនាការរបស់ អៀង ធីរិទ្ធ (“សេចក្តីសម្រេចដែលរងការជំទាស់”)[3] អមដោយសំណើមួយសុំផ្អាកជាបន្ទាន់នូវកិច្ចដំណើរការនីតិវិធី (“សំណើសុំផ្អាក”)។

២. ឥឡូវនេះ សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) ពន្យារពេលដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបន្ថែមដើម្បីគាំទ្រចំពោះបណ្តឹងសាទុក្ខនេះ។

## II. អំណះអំណាង

៣. អនុលោមតាមវិធាន ៨២(៦) នៃវិធានផ្ទៃក្នុង សំណើសុំផ្អាកនិងបណ្តឹងសាទុក្ខស្របគ្នានេះបានដាក់យ៉ាងត្រឹមត្រូវនៅក្នុងរយៈពេល២៤ម៉ោង បន្ទាប់ពីការជូនដំណឹងអំពីសេចក្តីសម្រេចដែលរងការជំទាស់។

៤. អង្គជំនុំជម្រះ មានសិទ្ធិផ្តល់ការអនុញ្ញាតឲ្យមានការពន្យារពេល។ សហព្រះរាជអាជ្ញាសូមយោងវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងដែលចែងថា តាមពាក្យសុំរបស់ភាគីពាក់ព័ន្ធ អង្គជំនុំជម្រះអាចៈ

*(ក) ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់។*

*(ខ) ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថា ត្រឹមត្រូវសមហេតុផល។*

៥. អង្គជំនុំជម្រះនេះ ក្នុងការអនុញ្ញាតឲ្យធ្វើសំណើមួយស្រដៀងគ្នានេះពីសហព្រះរាជអាជ្ញា ទាក់ទងនឹង សេចក្តីសំរេចពីលើកមុនរបស់អង្គជំនុំជម្រះដើម្បីធ្វើការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធិ

---

[1] វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៨) ដែលបានកែសម្រួលនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១, (“វិធាន”)។

[2] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៧) ដែលបានកែសម្រួលនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១។

[3] **E138/1/10** សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១។

("ជនជាប់ចោទ")ពីមន្ទីរឃុំឃាំងដោយឥតលក្ខខណ្ឌ បានយល់ឃើញអំពីៈ "...សារៈសំខាន់ថតើ ឬ ស្ថិតនៅក្រោមលក្ខខណ្ឌអ្វី ប្រសិនបើមានដែលជនជាប់ចោទគួរតែត្រូវធ្វើការដោះលែងពីមន្ទីរឃុំឃាំង និងដោះលែងភ្លាមក្នុងពេលដ៏ខ្លីបែបនេះ..."[4]។

៦. បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា គឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកំរិតនៃលក្ខខណ្ឌដែលត្រូវយកមកអនុវត្តចំពោះដីកាបង្គាប់ឲ្យដោះលែងជនជាប់ចោទណាមួយ ដែលបានប្រឈមមុខនឹងបទចោទប្រកាន់នានាដែលមានស្ថានទម្ងន់ជាពិសេសដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មផ្សេងៗ ដែលជាក្ដីការព្រួយបារម្ភរបស់សហគមន៍អន្តរជាតិទាំងមូល។ ក្របខណ្ឌនៃពេលវេលាជាធរមានសំរាប់ការប្ដឹងសាទុក្ខបានកំរិតយ៉ាងខ្លាំងដល់លទ្ធភាពរបស់សហព្រះរាជអាជ្ញា ក្នុងការផ្ដល់ជូនអង្គជំនុំជម្រះនូវការដាក់សេចក្ដីសន្និដ្ឋានដ៏ទូលំទូលាយមួយ ដែលថ្លែងអំពីទឡ្ហីករណ៍ខាងផ្នែកច្បាប់ឲ្យបានយ៉ាងលំអិតគ្រប់គ្រាន់ និងដោយយោងទៅលើឯកសារពាក់ព័ន្ធនានាដែលគាំទ្រ។

## III. **សំណើ**

៧. អាស្រ័យដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះមេត្តាអនុញ្ញាតផ្ដល់ពេលវេលាក្នុងការដាក់សារណាបន្ថែមដើម្បីគាំទ្រដល់បណ្ដឹងសាទុក្ខនេះនៅក្នុងរយៈពេលប្រាំពីរ(៧)ថ្ងៃ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

[4]ឯកសារលេខ **E138/1/3** សេចក្ដីសំរេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំដាក់សារណាបន្ថែម និងសេចក្ដីណែនាំពាក់ព័ន្ធនឹងការដាក់បណ្ដឹងសាទុក្ខ, ចុះថ្ងៃទី២១ វិច្ឆិកា ២០១២។